# ការគ្រប់គ្រងតាមគោលការណ៍នៃវិមជ្ឈការឯកភាព

មាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(ច្បាប់រៀបចំអង្គការ) ដែលបានចូលជាធរមាននៅក្នុងឆ្នាំ២០០៨ បានកំណត់ថា "*រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ*"។ ទោះជាយ៉ាងនេះក្តី យើងសង្កេតឃើញថា រហូតមកទល់បច្ចុប្បន្ននេះ ការគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដែលធ្វើឡើងដោយរដ្ឋបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិហាក់នៅពុំទាន់ដំណើរការរលូន និងពុំទាន់ទទួលបានលទ្ធផលល្អប្រសើរនៅឡើយ។ អត្ថបទនេះនឹងសាកល្បងធ្វើការពិភាក្សាអំពីបញ្ហានេះ ក៏ដូចលើកឡើងនូវអនុសាសន៍ដើម្បីពង្រឹងការអនុវត្ត។

**និយមន័យ**

សន្ទានុក្រមដែលភ្ជាប់ជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់និយមន័យនៃពាក្យ ***រដ្ឋបាលឯកភាព*** ថា "*គឺជាការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រងចាត់ចែងមុខងារ និងធនធាន រាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន ហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន*"។

យោងតាមនិយមន័យខាងលើ នៅក្នុង *រដ្ឋបាលឯកភាព*មានពាក្យគន្លឹះ០២គឺ *ម្ចាស់ការ* និង*សម្របសម្រួលប្រកបដោយប្រសិទ្ធភាព*។ *ម្ចាស់ការ*សំដៅលើក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញក្នុងការចាត់ចែងមុខងារ ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិរបស់រដ្ឋបាលដោយខ្លួនឯង។ *សម្របសម្រួលប្រកបដោយប្រសិទ្ធភាព* សំដៅលើក្រុមប្រឹក្សាមានសមត្ថភាពគ្រប់គ្រាន់ អាចកៀរគរណែនាំតម្រង់ទិសស្ថាប័នមានសមត្ថកិច្ចទាំងអស់ ជាពិសេសមន្ទីរ អង្គភាពជំនាញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការពិភាក្សាពិគ្រោះយោបល់ និងដោះស្រាយរួមគ្នាអំពីការផ្តល់សេវាកម្ម និងការអភិវឌ្ឍនានា រួមទាំងការរៀបចំផែនការរបស់ស្ថាប័ន អង្គភាព និងការដោះស្រាយបញ្ហាប្រឈមនានានៅក្នុងមូលដ្ឋាន សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារតាមរយៈការធ្វើ សមាហរណកម្មនូវរាល់សកម្មភាព និងធនធានដែលមានទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

យើងអាចនិយាយម្យ៉ាងទៀតថា ការគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព គឺមិនតម្រូវឱ្យតែរដ្ឋបាលថ្នាក់ក្រោមជាតិតែឯងត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនោះឡើយ ក្នុងនោះក៏តម្រូវឱ្យការផ្តល់សេវា និងការអភិវឌ្ឍដែលធ្វើឡើងដោយមន្ទីរ អង្គភាពនានាដែលបំពេញការងារនៅក្នុងមូលដ្ឋានត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋផងដែរ។ មានន័យថា មន្ទីរ អង្គភាពនានាដែលបម្រើសេវានៅមូលដ្ឋានមានកាតព្វកិច្ចមិនត្រឹម

តែធ្វើតាមផែនការ ឬការណែនាំពីក្រសួង ស្ថាប័ន ខ្សែបណ្ដោយរបស់ខ្លួនប៉ុណ្ណោះទេ គឺត្រូវគិតគូរផងដែរអំពីការបម្រើសេវា ដែលមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

សរុបមក ការគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព គឺជាប្រព័ន្ធ និងកិច្ចដំណើរការដែលក្រុមប្រឹក្សាមានសមត្ថភាពធ្វើការកៀរគរ ប្រមូលផ្ដុំ និងប្រើប្រាស់ធនធានពីគ្រប់មជ្ឈដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងគោលបំណងលើកកម្ពស់ការផ្ដល់សេវា និងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ របៀបរបបគ្រប់គ្រងនេះ នឹងនាំមកនូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ការគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះមានដូចជា ការបញ្ចៀសបាននូវការធ្វើផែនការជាន់គ្នា ការប្រើប្រាស់ធនធានមនុស្ស និងហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព ការលើកកម្ពស់កិច្ចសហការ និងការផ្លាស់ប្ដូរព័ត៌មានគ្នាបានល្អប្រសើរ ព្រមទាំងការដកពិសោធន៍ពីគ្នាទៅវិញទៅមក ជាដើម។

ទន្ទឹមនេះ គួរចាប់អារម្មណ៍និងកត់សំគាល់ថានៅក្នុងការពន្យល់ខាងលើនេះយើងប្រើពាក្យ 'ក្រុមប្រឹក្សា'។ ការប្រើពាក្យនេះ ក៏អាចជាការឆ្លុះបញ្ចាំងនូវប្រព័ន្ធគ្រប់គ្រងថ្មីមួយ ដែលខុសប្លែកពីពេលមិនមានក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោត។ ក្នុងប្រព័ន្ធថ្មីនេះ ក្រុមប្រឹក្សាគឺជាអ្នកធ្វើសេចក្ដីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ពាក់ព័ន្ធការគ្រប់គ្រងចាត់ចែងកិច្ចការនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំណែកគណៈអភិបាល គឺជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង ចាត់ចែងអនុវត្តរាល់សេចក្ដីសម្រេចទាំងនោះ ក្នុងនាមក្រុមប្រឹក្សា។

## វឌ្ឍនភាព និងបញ្ហាប្រឈម

បន្ទាប់ពីការធ្វើសមាហរណកម្មនៃមន្ត្រីសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងឆ្នាំ២០០៩ស្របតាមច្បាប់រៀបចំអង្គការ របៀបរបបគ្រប់គ្រងថ្មីតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យដំណើរការនៅតាមរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ គិតមកទល់ពេលនេះ ប្រព័ន្ធថ្មីនេះបានដំណើរការប្រមាណជា០៧ឆ្នាំកន្លងមកហើយ។ នៅក្នុងរយៈពេលនេះ លិខិតបទដ្ឋានពាក់ព័ន្ធជាច្រើន ក្រៅពីច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងក្នុងគោលដៅគាំទ្រដល់ការរៀបចំប្រព័ន្ធ និងកិច្ចដំណើរការនៃ គ្រប់គ្រងប្រព័ន្ធថ្មីនេះ ក្នុងនោះលិខិតបទដ្ឋានសំខាន់ៗរួមមាន៖

- អនុក្រឹត្យលេខ២១៥ និង២១៦ ពាក់ព័ន្ធតួនាទីភារកិច្ចនិងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ២១៧ និង២១៨ និងសេចក្ដីណែនាំលេខ០៣៥ និង០៣៦ ពាក់ព័ន្ធការបង្កើតការរៀបចំនិងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- អនុក្រឹត្យលេខ២១៩ និងប្រកាសអន្តរក្រសួងលេខ២៤១៧និង៣៥១៤ពាក់ព័ន្ធការកសាងផែនការអភិវឌ្ឍនប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ៤៩៧ ពាក់ព័ន្ធការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការ

តែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ....ជាដើម។

ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធខាងលើ យើងពិនិត្យឃើញថា អភិបាលមានសិទ្ធិអំណាចស្របតាមការគ្រប់គ្រង តាមគោលការណ៍នៃវដ្ឋបាលឯកភាព តាមរយៈការផ្តល់តួនាទីដល់អភិបាលធ្វើជាតំណាង ក្រសួង ស្ថាប័ននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សានីមួយៗ។

ក្នុងនាមជាតំណាងក្រសួង ស្ថាប័ន អភិបាលមានសិទ្ធិក្នុងការណែនាំ សម្របសម្រួល តម្រង់ទិសមន្ទីរ អង្គភាព ខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា (មាត្រា១៥៤ នៃច្បាប់រៀបចំអង្គការ)។ម្យ៉ាងទៀត អភិបាលក៏មានសិទ្ធិក្នុងការពិនិត្យ និងផ្តល់យោបល់ជាមុន ទៅលើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ អង្គភាពរបស់ក្រសួងស្ថាប័នប្រចាំនៅរាជធានី ខេត្ត មុនប្រធានមន្ទីរ អង្គភាពបញ្ជូនទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី (មាត្រា៣៥ នៃអនុក្រឹត្យ២១៥ និង២១៦)។ លើសពីនេះទៀត ក្នុងករណីប្រធានមន្ទីរ អង្គភាពណាមួយមិនអនុវត្តតាមការណែនាំ ឬតម្រង់ទិសអភិបាលរាជធានី ខេត្ត មានសិទ្ធិលើកសំណើទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចរបស់ប្រធានមន្ទីរ អង្គភាពនោះបាន(មាត្រា១១ នៃអនុក្រឹត្យលេខ៤៩៧)។ ទន្ទឹមនេះ អភិបាលរាជធានី ខេត្ត ក៏បានទទួលប្រតិភូកម្មអំណាចក្នុងការចេញដីកា ដើម្បីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននានាដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានមន្ទីរ ឬអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានីខេត្ត និងចាប់ពីថ្នាក់ប្រធានការិយាល័យជំនាញ ឬថ្នាក់ប្រហាក់ប្រហែលចុះក្រោមនៅថ្នាក់ក្រុង ស្រុកខណ្ឌ(មាត្រា១២ និង១៣ នៃអនុក្រឹត្យលេខ៤៩៧)។

ដោយឡែកក្នុងតួនាទីជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អភិបាល អាចប្រើប្រាស់យន្តការនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនេះ ដើម្បីធ្វើការពិភាក្សា ពិគ្រោះយោបល់ ផ្លាស់ប្តូរបទពិសោធន៍ ក៏ដូចជាណែនាំ សម្របសម្រួល តម្រង់ទិស ឬដោះស្រាយបញ្ហាប្រឈមនានា ដែលកើតមានឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ពីព្រោះនៅក្នុងសមាសភាពនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ប្រធានមន្ទីរ អង្គភាពជំនាញទាំងអស់នៅក្នុងដែនសមត្ថកិច្ចគឺជាសមាជិក ហើយគណៈកម្មាធិការនេះមានរបបប្រជុំយ៉ាងតិចពីរខែម្តង និងអាចកោះប្រជុំតាមការចាំបាច់។ ទន្ទឹមនេះ ក្នុងដំណើរការនៃការ

**សមាសភាពគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

| | |
|---|---|
| - អភិបាលខេត្ត | *ប្រធាន* |
| - អភិបាលរងខេត្ត០១រូប | *អនុប្រធាន* |
| - នាយករដ្ឋបាលសាលាខេត្ត | *សមាជិកអចិន្ត្រៃយ៍* |
| - សមាជិកក្រុមប្រឹក្សាខេត្តយ៉ាងតិច០២រូប | *សមាជិក* |
| - ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត | *សមាជិក* |
| - នាយកទីចាត់ការសាលាខេត្ត | *សមាជិក* |
| - អភិបាលក្រុង ស្រុកក្នុងខេត្ត | *សមាជិក* |
| - តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ប្រចាំខេត្ត០២រូប | *សមាជិក* |
| - តំណាងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ០១រូប | *សមាជិក* |

កសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្របខ័ណ្ឌច្បាប់បានតម្រូវឱ្យដាក់ឆ្លងឯកសារទាំងនេះជូនគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសពិនិត្យជាមុនសិន មុននឹងដាក់ជូនក្រុមប្រឹក្សាពិនិត្យសម្រេច ដែលតាមរយៈនេះ អភិបាល ក្នុងនាមជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសអាចធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់មន្ទីរ អង្គភាពនានានៅក្នុងដែនសមត្ថកិច្ច ដើម្បីរៀបចំផែនការឱ្យមានសង្គតិភាព និងបំពេញឱ្យគ្នាទៅវិញទៅមកជាមួយនឹងផែនការរបស់រដ្ឋបាលខេត្ត។

សរុបមក បើពិនិត្យទៅលើយន្តការដែលមានបច្ចុប្បន្ន យើងឃើញថា អភិបាលរាជធានី ខេត្តមានសិទ្ធអំណាច និងឥទ្ធិពលក្នុងការសម្របសម្រួល ឬ



*កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៃក្រុមប្រឹក្សាខេត្តបាត់ដំបង*

ណែនាំតម្រង់ទិសមន្ទីរអង្គភាពនៅក្នុងដែន សមត្ថកិច្ចរបស់ក្រុមប្រឹក្សាបានប្រកបដោយប្រសិទ្ធភាព។

ហេតុនេះ យើងអាចនិយាយបានថា ប្រព័ន្ធនៃការគ្រប់គ្រងដែលបានរៀបចំឡើងវិញមានលក្ខណៈឆ្លើយតបទៅនឹងរបៀបរបបនៃការគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព។

ទោះជាយ៉ាងនេះក្តី នៅក្នុងការអនុវត្តជាក់ស្តែងកន្លងមក លទ្ធផលទទួលបានហាក់នៅមានកម្រិត និងពុំទាន់ឆ្លើយតបពេញលេញទៅនឹងស្មារតីនៃច្បាប់រៀបចំអង្គការនៅឡើយ។

នៅតាមរដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិមានក្រុមប្រឹក្សាកើតឡើងពីការបោះឆ្នោតជាតំណាងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចប៉ុន្តែក្រុមប្រឹក្សាទាំងនោះនៅពុំទាន់មានស្វ័យភាពធនធាន និងមុខងារសមស្រប ដែលអាចគ្រប់គ្រង ចាត់ចែងកិច្ចការនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ និងកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋាននៅឡើយ។ បច្ចុប្បន្ន ធនធានថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានគម្លាតឆ្ងាយពីតម្រូវការដែលមានប្រមាណតែ ៩%(ឆ្នាំ២០១៣)នៃថវិកាចរន្តរបស់ជាតិប៉ុណ្ណោះ ហើយមុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិបច្ចុប្បន្ន ក៏ពុំទាន់បានផ្ទេរជាដុំកំភួននៅឡើយ ដោយភាគច្រើនគឺមានតែមុខងារដែលជាអាណត្តិទូទៅតែប៉ុណ្ណោះ។

ម្យ៉ាងទៀត ការកៀរគរធនធានដែលមាននៅក្នុងដែនសមត្ថកិច្ចក្នុងគោលបំណងរួមគ្នាដោះស្រាយបញ្ហាជាអាទិភាពនៅមូលដ្ឋាន ក៏នៅពុំទាន់ទទួលបានលទ្ធផលល្អនៅឡើយ ដោយសារម្យ៉ាងសមត្ថភាពនៃការសម្របសម្រួលក្នុងចំណោមមន្ទីរ អង្គភាពជំនាញ នៅក្នុងដែនសមត្ថកិច្ចដោយរដ្ឋបាលនីមួយៗនៅពុំទាន់បានល្អប្រសើរ។ ម្យ៉ាងទៀត អាចដោយសារមន្ទីរ អង្គភាពជំនាញ ព្រមទាំង

ក្រសួង ស្ថាប័នមួយចំនួននៅពុំទាន់យល់ច្បាស់អំពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលធ្វើឱ្យការចូលរួម និងការសហការអនុវត្តនៅមានកម្រិត។

**អនុសាសន៍**

ផ្អែកលើធនធានមនុស្ស និងហិរញ្ញវត្ថុ ព្រមទាំងសិទ្ធិអំណាចដែលរដ្ឋបាលនីមួយៗមានបច្ចុប្បន្ន វិធានការចំពោះមុខដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព គឺតាមរយៈ *ការពង្រឹងសមត្ថភាពសម្របសម្រួលរបស់ក្រុមប្រឹក្សាទៅលើសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀតដែលធ្វើឡើងដោយមន្ទីរ អង្គភាពជំនាញនៅក្នុងដែនសមត្ថកិច្ច ដើម្បីកៀរគរ និងប្រើប្រាស់ធនធានដែលមានឱ្យចំគោលដៅ និងមានប្រសិទ្ធភាព សំដៅរួមគ្នាឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានជាអតិបរមា។*

ខាងក្រោមនេះ ជាអនុសាសន៍មួយចំនួនដើម្បីពង្រឹងសមត្ថភាពសម្របសម្រួលរបស់រដ្ឋបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖

***ឈ្វេងយល់អំពីតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ***។ ក្នុងពេលដែលធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិត មិនអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋានដែលមានទំហំធំ ការកៀរគរ និងប្រើប្រាស់ធនធានឱ្យចំគោលដៅប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិគឺជាកត្តាគន្លឹះដ៏ប្រសើរបំផុត ក្នុងការលើកកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋនៅមូលដ្ឋាន។ ក្នុងន័យនេះ គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សា ត្រូវខិតខំឈ្វេងយល់ឱ្យបានច្បាស់លាស់ និងស៊ីជម្រៅអំពីតម្រូវការជាអាទិភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ច ដើម្បីប្រមូលហេតុផល និងសក្ខីកម្មឱ្យបានជាក់លាក់ និងសមស្របសម្រាប់ធ្វើការបញ្ចុះបញ្ចូល ក៏ដូចណែនាំនិងតម្រង់ទិសដល់អ្នកពាក់ព័ន្ធទាំងអស់ ដែលបម្រើសេវានៅក្នុងមូលដ្ឋាន។ បច្ចុប្បន្ននៅរដ្ឋបាលថ្នាក់ក្រោមជាតិមាន



*សកម្មភាពចូលរួមរបស់ប្រជាពលរដ្ឋក្នុងវេទិកាសាធារណៈ*

យន្តការជាច្រើនដែលគណៈអភិបាលអាចប្រើប្រាស់ដើម្បីជួបប្រាស្រ័យ និងឈ្វេងយល់ពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក្នុងនោះមានដូចជា វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ដែលធ្វើឡើងជារៀងរាល់ឆ្នាំនៅតាមមូលដ្ឋាន វេទិកាភូមិ-ឃុំមានសុវត្ថិភាព ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា ជាដើម។ល។ ក្រៅពីយន្តការទាំងនេះ រដ្ឋបាលនីមួយៗ ក៏ត្រូវយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការ

រៀបចំមធ្យោបាយផ្សេងៗទៀត ដើម្បីងាយស្រួលក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ក៏ដូចជាងាយស្រួលឱ្យប្រជាពលរដ្ឋទាក់ទងមករដ្ឋបាលនៅពេលមានសំណើ សំណូមពរផងដែរ។

*ព្យាយាមប្រើប្រាស់យន្តការគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស នៅក្នុងការបំពេញការងារ*។ អនុក្រឹត្យលេខ២១៧ និង២១៨ បានកំណត់អំពីរបៀបរបបការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដែលក្នុងនោះគណៈកម្មាធិការនេះត្រូវជួបប្រជុំយ៉ាងតិចពីរខែម្តង និងអាចកោះប្រជុំតាមការចាំបាច់។ ផ្អែកតាមរបៀបរបបការងារដែលបានកំណត់នៅក្នុងអនុក្រឹត្យទាំងនេះ អភិបាលក្នុងនាមជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានតួនាទី និងសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការរៀបចំយន្តការ ក៏ដូចចាត់ចែងការងារជាក់ស្តែងនានាបន្ថែមទៀត ដើម្បីធានាឱ្យគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អាចដំណើរការទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព ក្នុងនោះដំបូងបង្អស់ គឺត្រូវធ្វើការផ្សព្វផ្សាយដល់សមាជិកទាំងអស់ នៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីឱ្យបានជ្រួតជ្រាបអំពីតួនាទី ភារកិច្ចរបស់សមាជិកម្នាក់ៗ ក៏ដូចជាការពង្រីកនូវតួនាទី ភារកិច្ច របៀបរបបការងារ និងសារសំខាន់នៃគណៈកម្មាធិការនេះ។

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មានសមាសភាពមកពីគ្រប់មន្ទីរ អង្គភាពជំនាញនៅក្នុងដែនសមត្ថកិច្ច។ ហេតុនេះ ការប្រើប្រាស់យន្តការនេះ ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមនៅក្នុងមូលដ្ឋាន គឺមានលក្ខណៈសមហេតុផល និងមានប្រសិទ្ធភាពបំផុត។ ក្រៅពីកាលានុវត្តដែលច្បាប់ និងលិខិតបទដ្ឋានបានកំណត់ មានកាលានុវត្តជាច្រើនទៀត ដែលយើងអាចប្រើប្រាស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីជាយន្តការក្នុងការបំពេញការងារ។ ឧទាហរណ៍ ករណីជួបប្រទះគ្រោះរាំងស្ងួតនៅមូលដ្ឋាន អភិបាល ក្នុងនាមជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អាចរៀបចំកោះប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីរួមគ្នារិះរកមធ្យោបាយសរុប កម្លាំងសរុប ក្នុងការដោះស្រាយបញ្ហារាំងស្ងួតនេះ ក្នុងនោះមានដូចជា ការរៀបចំក្រុមការងារចំពោះកិច្ចដែលមានសមាសភាពមកពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធជាដើម។ម្យ៉ាងទៀត ក្នុងការរៀបចំបញ្ញត្តិនានាសម្រាប់ការគ្រប់គ្រងនៅមូលដ្ឋាន អភិបាលក៏អាចប្រើប្រាស់យន្តការនេះ ដើម្បីជាប្រភពធនធាន ឬជាធាតុចូលសម្រាប់ការសិក្សា ផ្តល់យោបល់ទៅលើការរៀបចំនោះដែរ ជាពិសេសពាក់ព័ន្ធការងារជំនាញដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

*ធ្វើការណែនាំ សម្របសម្រួល និងតាមដានត្រួតពិនិត្យរាល់សកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍនានានៅមូលដ្ឋានដែលធ្វើឡើងដោយមន្ទីរ អង្គភាពជំនាញនៅក្នុងដែនសមត្ថកិច្ច*។ នេះជាកិច្ចការសំខាន់ ដែលធានាឱ្យមានរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ។ អនុក្រឹត្យលេខ២១៧ និង២១៨ បានកំណត់អំពីតួនាទីសំខាន់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្នុងការផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលលើកិច្ចការសំខាន់ៗមួយចំនួន ដែលក្នុងចំណោមកិច្ចការទាំងនោះ កិច្ចការពាក់ព័ន្ធជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានានៅក្នុងដែនសមត្ថកិច្ចមានដូចខាងក្រោម៖

- ការដាក់បញ្ចូលផែនការអភិវឌ្ឍន៍ និងថវិការបស់មន្ទីរអង្គភាពជំនាញទៅក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា
- ការរៀបចំសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា
- ការរៀបចំសេចក្ដីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា
- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន
-ការសម្របសម្រួលការផ្ដល់សេវានិងការអភិវឌ្ឍដែលផ្ដល់ដោយក្រសួង ស្ថាប័ន ឬដោយមន្ទីរអង្គភាព របស់ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សា ជាមួយក្រសួង ស្ថាប័នមន្ទីរ អង្គភាពជំនាញនានា
- ការផ្ដល់អនុសាសន៍ដល់ក្រសួង ស្ថាប័ននានាដើម្បីកែលម្អការផ្ដល់សេវា និងការអភិវឌ្ឍស្របតាមតម្រូវការរបស់មូលដ្ឋាន

ដូចមានបញ្ជាក់នៅខាងលើ ដើម្បីធានាឱ្យមានការគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ច្បាប់បានកំណត់ឱ្យមានទំនាក់ទំនងដ៏ចាំបាច់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ អង្គភាពជំនាញ នោះគឺការដាក់បញ្ចូលផែនការអភិវឌ្ឍន៍ និងថវិកាប្រចាំឆ្នាំរបស់មន្ទីរ អង្គភាពជំនាញ ទៅក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា ហើយត្រូវឆ្លុះបញ្ចាំងនៅក្នុងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា។ តាមរយៈការធ្វើសមាហរណកម្មនេះ ក្រុមប្រឹក្សាអាចធ្វើការកៀរគរ ក៏ដូចតម្រង់ទិសដល់មន្ទីរ អង្គភាពជំនាញក្នុងការប្រើប្រាស់ធនធានឱ្យចំគោលដៅ ដែលឆ្លើយតបទៅនឹងសេចក្ដីត្រូវការជាអាទិភាព និងចាំបាច់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ក្នុងន័យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការធ្វើសមាហរណកម្ម អភិបាល ក្នុងនាមជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវយកចិត្តទុកដាក់លើ *ពេលវេលា*និង *ការត្រៀមលក្ខណៈ* ឱ្យបានគ្រប់ជ្រុងជ្រោយសម្រាប់កោះប្រជុំគណៈកម្មា-ធិការសម្របសម្រួលបច្ចេកទេសឱ្យទាន់ពេលវេលាដើម្បីណែនាំ និងតម្រង់ទិសអំពីការរៀបចំផែនការអភិវឌ្ឍន៍ និងថវិកាប្រចាំឆ្នាំរបស់មន្ទីរ អង្គភាពជំនាញ ដោយធានាឱ្យមានសង្គតិភាពជាមួយគោលនយោបាយសេវាសាធារណៈ និងផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សា ជាពិសេសកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា។ ម្យ៉ាងទៀត អភិបាលអាចធ្វើការពិភាក្សា និងពិគ្រោះយោបល់ឱ្យបានស៊ីជម្រៅនៅក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស អំពីរបៀបរបប ក៏ដូចវិធាននៃកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល ជាមួយមន្ទីរអង្គភាពជំនាញនៅក្នុងដែនសមត្ថកិច្ច ដើម្បីធានាបាននូវការធ្វើផែនការ ក៏ដូចកិច្ចសហការជាប្រចាំមួយដែលមានលក្ខណៈសមាហរណកម្ម ហើយឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

***ពង្រឹងគណនេយ្យភាពរបស់មន្ត្រីរាជការនៃមន្ទីរអង្គភាពជំនាញនៅក្នុងដែនសមត្ថកិច្ច ចំពោះអភិបាល ក្នុងនាមជាតំណាងក្រសួង ស្ថាប័ននៅក្នុងដែនសមត្ថកិច្ច។*** ផ្អែកតាមអនុក្រឹត្យលេខ ៤៩៧ រាជរដ្ឋាភិបាលបានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្ត ក្នុងការតែងតាំង ការផ្លាស់ប្ដូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលកំពុង

បំពេញការងារនៅថ្នាក់ក្រោមជាតិ រួមទាំងមន្ត្រីរាជការស៊ីវិលកំពុងបំពេញការងារនៅតាមមន្ទីរ អង្គភាពជំនាញនានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ដែលមានតួនាទីចាប់ពីថ្នាក់អនុប្រធានមន្ទីរ អង្គភាពចុះ ព្រមទាំងអាចស្នើបញ្ចប់ភារកិច្ច ឬស្នើតែងតាំងប្រធានមន្ទីរ អង្គភាពជំនាញជុំវិញរាជធានី ខេត្ត ផងដែរ។ តាមរយៈការធ្វើប្រតិភូកម្មអំណាចនេះ អភិបាលរាជធានី ខេត្ត អាចមានលទ្ធភាពកាន់តែប្រសើរថែមទៀត ក្នុងការជំរុញមន្ទីរ អង្គភាពជំនាញឱ្យកាន់តែមានគណនេយ្យភាពចំពោះអភិបាលរាជធានី ខេត្ត ក៏ដូចរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ពីព្រោះប្រសិនបើមន្ទីរ អង្គភាពមិនអនុវត្តតាមការណែនាំ និងតម្រង់ទិសពីអភិបាលរាជធានី ខេត្ត ដោយគ្មានហេតុផលសមស្របទេ អភិបាលរាជធានី ខេត្តអាចចាត់វិធានការបន្តទៀត ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់ខ្លួន។ ម្យ៉ាងទៀត នៅក្នុងឱកាសនៃការពិនិត្យ និងផ្តល់យោបល់ទៅលើរបាយការណ៍របស់ប្រធានមន្ទីរ អង្គភាពជំនាញមុនបញ្ជូនទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នជំនាញ អភិបាលរាជធានី ខេត្តអាចធ្វើការណែនាំ ឬតម្រង់ទិសប្រធានមន្ទីរ អង្គភាពជំនាញ ឬធ្វើសំណើសំណូមពរទៅក្រសួង ស្ថាប័នជំនាញផងដែរ ដើម្បីធ្វើយ៉ាងណាឱ្យការបម្រើសេវារបស់ក្រសួង ស្ថាប័ននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា មានលក្ខណៈឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

សរុបមកវិញ បើទោះបីបច្ចុប្បន្ន មន្ទីរ អង្គភាពជំនាញនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្ថិតនៅជាខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នជំនាញយ៉ាងណាក្តី ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានដែលមានបច្ចុប្បន្ន បានផ្តល់ឱ្យក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិអំណាច និងយន្តការចាំបាច់មួយចំនួន ដែលក្រុមប្រឹក្សាអាចប្រើប្រាស់ដើម្បីលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនតាមគោលការណ៍នៃរដ្ឋបាលឯកភាព សំដៅរួមចំណែកក្នុងការជំរុញ និងធ្វើឱ្យចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី រដ្ឋបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិអាចបំពេញភារកិច្ចដោយទទួលជោគជ័យបាន គឺអាស្រ័យទៅលើភាពប៉ិនប្រសប់ ការច្នៃប្រឌិត និងគំនិតផ្តួចផ្តើមបន្ថែមទៀតរបស់ក្រុមប្រឹក្សានីមួយៗផងដែរ។